# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ៣11 អ.ប.ប

រាជធានីភ្នំពេញ, ថ្ងៃទី 27 ខែ 05 ឆ្នាំ២០០3

# ប្រកាស

## ស្តីពី

## ការរៀបចំ និង ការប្រព្រឹត្តទៅ
## របស់សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ

***

## ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈ រដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យ លេខ ៦៧ អនក្រ-បក ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យ លេខ ១២៩ អនក្រ-បក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០២ ស្តីពីការ គ្រប់គ្រង សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ
- យោងតាមការចាំបាច់របស់ក្រសួង

## សំរេច:

**ប្រការ ១.-**

រៀបចំបណ្តាសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគនិងការិយាល័យចំណុះនាយ[illegible] និង ភារៈកិច្ច ។

2

**ប្រការ ២.-**

សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគសរសេរអក្សរកាត់ "ស.ម.ស.ភ." គឺជាគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ សុខាភិបាលភូមិភាគ ដែលឋិតនៅក្រោមការគ្រប់គ្រងផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និង បច្ចេកទេស ដោយផ្ទាល់ពីក្រសួងសុខាភិបាល ។

**ប្រការ ៣.-**

ស.ម.ស.ភ.មានតួនាទីដឹកនាំ និងគ្រប់គ្រងសកម្មភាពបណ្តុះបណ្តាលនៅតាមបណ្តាខេត្តនានាក្នុងភូមិភាគរបស់ខ្លួន ។

**ប្រការ ៤.-**

ស.ម.ស.ភ.មានភារកិច្ចទទួលខុសត្រូវបណ្តុះបណ្តាលនៅក្នុងភូមិភាគចំនួន៤ដែលគ្រប់ដណ្តប់លើខេត្ត ដូចតទៅ :

- ស.ម.ស.ភ. ស្ទឹងត្រែង: ខេត្តស្ទឹងត្រែង ព្រះវិហារ រតនៈគិរី និង ខេត្តមណ្ឌលគិរី
- ស.ម.ស.ភ. បាត់ដំបង: ខេត្តបាត់ដំបង សៀមរាប ពោធិសាត់ បន្ទាយមានជ័យ ឧត្តរមានជ័យ និង ក្រុងប៉ៃលិន
- ស.ម.ស.ភ. កំពត : ខេត្តកំពត តាកែវ កោះកុង ក្រុងព្រះសីហនុ និងក្រុងកែប
- ស.ម.ស.ភ.កំពង់ចាម : ខេត្តកំពង់ចាម ព្រៃវែង កំពង់ធំ និង ខេត្តក្រចេះ

**ប្រការ ៥.-**

សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ ទទួលខុសត្រូវក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស ប្រកបដោយគុណភាព និងបង្កើនសមត្ថភាពមន្ត្រីសុខាភិបាលតាមរយៈការផ្តល់នូវចំណេះដឹង ជំនាញបច្ចេកទេស ការគ្រប់គ្រងសេវានិងការផ្លាស់ប្តូរអាកប្បកិរិយាវិជ្ជាជីវៈ ស្របតាមគោលនយោបាយយុទ្ធសាស្ត្ររបស់ក្រសួងសុខាភិបាល ។

**ប្រការ ៦.-**

ស.ម.ស.ភ. មាន ភារកិច្ចដូចខាងក្រោម:

-អភិវឌ្ឍន៍ផែនការបណ្តុះបណ្តាលមេសំរាប់ភូមិភាគរបស់ខ្លួនរួមមាន: ការរៀបចំកម្មវិធីសិក្សា ការប៉ាន់ប្រមាណតំរូវការបណ្តុះបណ្តាល ការធ្វើផែនការសកម្មភាពបណ្តុះបណ្តាល ការដាក់ឱ្យអនុវត្តការបណ្តុះបណ្តាល ការតាមដាន និង វាយតំលៃការបណ្តុះបណ្តាល ។

-អភិវឌ្ឍន៍ធនធានមនុស្សសុខាភិបាលតាមរយៈការបណ្តុះបណ្តាលមូលដ្ឋាន ក្រោយមូលដ្ឋានឯកទេសគិលានុបដ្ឋាក ឯកទេសឆ្មប និង កម្មវិធីបណ្តុះបណ្តាលអមវេជ្ជសាស្ត្រផ្សេងៗ ទៀត

-បង្កើនសមត្ថភាពមន្ត្រីសុខាភិបាល តាមរយៈការបណ្តុះបណ្តាលបន្តវគ្គវិក្រិត្យការ និងវគ្គបណ្តុះបណ្តាលខ្លីៗ

-ផ្តល់ការបណ្តុះបណ្តាលវិធីសាស្ត្របង្រៀនដល់គ្រូថ្នាក់ខេត្ត ដែលនៅក្នុងភូមិភាគ និងផ្តល់ការឧបត្ថម្ភ

ផ្នែកបច្ចេកទេសព្រមទាំងឧបករណ៍ជំនួយបង្រៀន ដើម្បីបង្កើនគុណភាពនៃការបណ្តុះបណ្តាលបន្ត នៅថ្នាក់ខេត្ត និងស្រុកប្រតិបត្តិ ។

-តាមដាននិងវាយតំលៃអំពីផលប៉ះពាល់និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងគ្រប់គ្រងការងារបណ្តុះបណ្តាល ដោយជំរុញការប្រើប្រាស់ ប្រព័ន្ធទិន្នន័យធនធានមនុស្ស សុខាភិបាល ។

**ប្រការ ៧.-**

ស.ម.ស.ភ. មានការិយាល័យចំនួន ៣ ជាសេនាធិការ គឺ:

- ការិយាល័យរដ្ឋបាល និងបុគ្គលិក
- ការិយាល័យគណនេយ្យ
- ការិយាល័យបច្ចេកទេស ។

**ប្រការ ៨.-**

ការិយាល័យរដ្ឋបាល និងបុគ្គលិក ដឹកនាំដោយប្រធាន ១រូប និង អនុប្រធាន ១ ឬច្រើនរូប ដែលមានផ្នែកចំនួន២ គឺ: ផ្នែករដ្ឋបាលទូទៅ និងផ្នែកបុគ្គលិក

**ក.** ផ្នែករដ្ឋបាលទូទៅមានតួនាទី :

- សំរបសំរួលរាល់ការងាររដ្ឋបាលរបស់សាលា
- គ្រប់គ្រង និង ចរាចរផ្សព្វផ្សាយឯកសាររដ្ឋបាលផ្សេងៗ
- សំរបសំរួល និងធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល
- សំរបសំរួលការងារសង្គម
- រៀបចំសេចក្តីណែនាំ ជានិយាម ផ្នែករដ្ឋបាលសំរាប់ការគ្រប់គ្រងសាលា
- សរុប និងធ្វើរបាយការណ៍សកម្មភាពបណ្តុះបណ្តាល និងសកម្មភាពផ្សេងៗរបស់សាលា
- គ្រប់គ្រងរាល់កិច្ចការទាក់ទងដល់សិស្ស
- ទទួលខុសត្រូវតាមនិតិវិធីរដ្ឋបាល និងថែរក្សាការពារចលនទ្រព្យ និងអចលនទ្រព្យ ធ្វើគំរោង ចំណាយក្នុងការថែទាំជួសជុល ដោយសហការជាមួយការិយាល័យពាក់ព័ន្ធ ។

**ខ.** ផ្នែកបុគ្គលិក មានតួនាទី :

- គ្រប់គ្រងមន្ត្រីសាលាទាំងអស់ ដោយរៀបចំស្ថិតិបុគ្គលិក និងកំនត់ពីតំណែងនិងមុខងារបុគ្គលិក
- គ្រប់គ្រងរាល់ការងារបុគ្គលិក

**ប្រការ ៩.-**

ការិយាល័យគណនេយ្យ ដឹកនាំដោយប្រធាន ១រូប និងអនុប្រធាន ១ ឬច្រើនរូប ។ ការិយាល័យនេះមាន

ផ្នែកចំនួន ២ គឺៈ ផ្នែកគណនេយ្យ និងផ្នែកផ្គត់ផ្គង់

ក. ផ្នែកគណនេយ្យ :

-រៀបចំផែនការថវិកា គំរោងផែនការចំណាយ និងការតាមដានបញ្ជីចំណូល ចំណាយរបស់ សាលា

-គណនេយ្យកម្ម

ខ. ផ្នែកផ្គត់ផ្គង់ :

-គ្រប់គ្រង និងធ្វើបញ្ជីសារពើភ័ណ្ឌ ទ្រព្យសម្បត្តិរបស់សាលា

-ការងារសន្តិសុខ

-ការងារផ្គត់ផ្គង់

**ប្រការ ១០.-**

ការិយាល័យបច្ចេកទេស ដឹកនាំដោយប្រធាន ១រូប និងអនុប្រធាន ១ ឬច្រើនរូប និងមានផ្នែកចំនួន ៤

- ផ្នែកបណ្តុះបណ្តាលមូលដ្ឋាន
- ផ្នែកបណ្តុះបណ្តាលបន្ត
- ផ្នែកបណ្តុះបណ្តាលក្រោយមូលដ្ឋាន
- ផ្នែកបណ្ណាល័យ ស្រាវជ្រាវ និងឯកសារ

ផ្នែកនិមួយៗទទួលបន្ទុកក្នុងការជំរុញឱ្យការបណ្តុះបណ្តាលដែលធ្វើឡើងដោយសាលា នៃភូមិភាគនិមួយៗ មានគុណភាពល្អ ។

ក. ផ្នែកបណ្តុះបណ្តាលមូលដ្ឋានៈ

-ទទួលខុសត្រូវក្នុងការគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលគិលានុបដ្ឋាក និង កម្មវិធីបណ្តុះបណ្តាល គិលានុបដ្ឋាក-ឆ្មបជំនួយ

ខ.ផ្នែកបណ្តុះបណ្តាលបន្តៈ

-ទទួលខុសត្រូវក្នុងការគ្រប់គ្រងរាល់ការបណ្តុះបណ្តាលបន្ត ចំពោះមន្ត្រីសុខាភិបាល រួមមានៈ កម្មវិធីសំណុំសកម្មភាពអប្បបរិមា និង កម្មវិធីសំណុំសកម្មភាពបង្គ្រប់មួយចំនួន វគ្គវិក្រិត្យការ វគ្គ បណ្តុះបណ្តាលខ្លី និងការបណ្តុះបណ្តាល វិធីសាស្ត្របង្រៀនដល់ក្រុមគ្រូ ។

គ.ផ្នែកបណ្តុះបណ្តាលក្រោយមូលដ្ឋានៈ

-ទទួលខុសត្រូវគ្រប់គ្រងលើកម្មវិធីបណ្តុះបណ្តាលឯកទេសសំរាប់គិលានុបដ្ឋាក ឆ្មប និងអមវេជ្ជសាស្ត្រ ទាំងអស់ ។

ឃ. ផ្នែកបណ្ណាល័យ ស្រាវជ្រាវ និងឯកសារៈ

-ទទួលខុសត្រូវក្នុងការផ្តល់ពត៌មាន ឯកសារយោង និងសំភារៈបរិក្ខារជំនួយសិក្សា ដើម្បីគាំទ្រ ធ្វើឱ្យប្រសើរឡើងដល់ការបង្រៀន និងការរៀន

-ទទួលខុសត្រូវ និងសហការអនុវត្តធ្វើសកម្មភាពស្រាវជ្រាវ

-ទទួលខុសត្រូវក្នុងការចងក្រងឯកសារ និងរក្សាទុកឯកសារ ។

**ប្រការ ១១.-**

អង្គការលេខរបស់ ស.ម.ស.ភ. មានចែងនៅក្នុងឧបសម្ព័ន្ធ ។

**ប្រការ ១២.-**

ស.ម.ស.ភ. មានរចនាសម្ព័ន្ធដឹកនាំ ដោយមានក្រុមប្រឹក្សាចំនួន ៣ ជាជំនួយគឺៈ

-ក្រុមប្រឹក្សាសំរបសំរួលភូមិភាគ

-ក្រុមប្រឹក្សាបច្ចេកទេស

-ក្រុមប្រឹក្សាវិន័យ

**ប្រការ ១៣.-**

ក្រុមប្រឹក្សាសំរបសំរួលភូមិភាគ មានភារកិច្ចសំរបសំរួលការអនុវត្តន៍រាល់ការបណ្តុះបណ្តាលនៅក្នុងភូមិភាគ។ ក្រុមប្រឹក្សានេះមាននាយកសាលាជាប្រធាន និងប្រធានឬអនុប្រធានមន្ទីរសុខាភិបាលខេត្ត-ក្រុងនៅក្នុងភូមិភាគជាសមាជិក។ ក្រុមប្រឹក្សានេះធ្វើការប្រជុំជាទៀងទាត់រាល់ត្រីមាសជាមួយនឹងក្រុមរបស់មន្ទីរសុខាភិបាលខេត្ត-ក្រុងនៅក្នុងភូមិភាគ ដែលមានថ្នាក់ដឹកនាំមន្ទីរ ប្រធានការិយាល័យបច្ចេកទេស និងប្រធានផ្នែកបណ្តុះបណ្តាលចូលរួម ។

**ប្រការ ១៤.-**

ក្រុមប្រឹក្សាបច្ចេកទេសទទួលខុសត្រូវក្នុងការអភិវឌ្ឍន៍ និងណែនាំការងារបច្ចេកទេស ។ ក្រុមប្រឹក្សានេះរួមមាន នាយកសាលាជាប្រធាន ប្រធានការិយាល័យបច្ចេកទេសជាអនុប្រធាន ប្រធានការិយាល័យរដ្ឋបាលបុគ្គលិកមន្ត្រី សាលាសំខាន់ៗ និងប្រធានមន្ទីរពេទ្យ ព្រមទាំង ប្រធានផ្នែកថែទាំនៃមន្ទីរពេទ្យខេត្តដែលពាក់ព័ន្ធក្នុងការធ្វើកម្មសិក្សាគ្លីនិកជាសមាជិក។ ក្រុមប្រឹក្សាធ្វើការប្រជុំរៀងរាល់ ២ខែម្តង ឬតាមសំណូមពរ ។

**ប្រការ ១៥.-**

ក្រុមប្រឹក្សាវិន័យមានការទទួលខុសត្រូវក្នុងការដាក់ចុះឱ្យអនុវត្តនូវបទបញ្ជារបស់សាលា និងជាអ្នកលើកសរសើរជូនរង្វាន់ ព្រមាន/ ពិន័យ ដើម្បីតាមដានវាយតំលៃការអនុវត្តន៍វិន័យរបស់សិស្ស។ ក្រុមប្រឹក្សានេះដឹកនាំដោយនាយករង១រូបជាប្រធាន ប្រធានការិយាល័យរដ្ឋបាលជាអនុប្រធាន មន្ត្រីសំខាន់ៗរបស់សាលា និងតំណាងសិស្សជាសមាជិក ។

**ប្រការ ១៦.-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ផ្នែកនានារបស់សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ[illegible]

និងការទទួលខុសត្រូវរបស់នាយករង គឺ ត្រូវកំណត់ដោយ នាយកសាលា ដោយផ្អែកលើសមត្ថភាព និង ជំនាញរបស់នាយករង ព្រមទាំងបន្ទុកការងាររបស់សាលា ។

**ប្រការ ១៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ១៨.-**

អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គនាយករដ្ឋបាលហិរញ្ញវត្ថុ អគ្គាធិការ នាយកសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ បាត់ដំបង ស្ទឹងត្រែង កំពត និងកំពង់ចាម ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ពេទ្យ. ហុង-ស៊ុនហួត**

**ចម្លងជូន**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
-គ្រប់សាលាខេត្ត-ក្រុង ពាក់ព័ន្ធ
-ខុទ្ទកាល័យក្រសួងសុខាភិបាល
-គ្រប់មន្ទីរសុខាភិបាលខេត្ត-ក្រុង
- ដូចប្រការ ១៨
-ឯកសារ ៣

# រចនាសម្ព័ន្ធសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ

